# (១៧)

# ប្រកាសស្តីពី

# ការប្រគល់សិទ្ធិជូនប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត និងប្រធានរតនាគាររាជធានី ខេត្ត

លេខៈ ២៣០ សហវ.ប្រក

ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣២០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៥

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិជូនប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រធានរតនាគាររាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រគល់សិទ្ធិជូនប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រធានរតនាគាររាជធានី ខេត្ត ចំពោះ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ការបង្កើតរដ្ឋទេយ្យបុរេប្រទាន ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងការតែងតាំងភ្នាក់ងារបើកផ្តល់នៅតាមមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងអនុវត្តថវិកាកម្មវិធីពេញលេញ ដូចខាងក្រោម÷

១). ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ពិនិត្យ និងចុះហត្ថលេខា រួមគ្នាជាមួយប្រធានមន្ទីរជំនាញរាជធានី ខេត្ត លើសេចក្តីសម្រេចស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទានរបស់មន្ទីរជំនាញរាជធានី ខេត្ត (ដូចមានកំណត់ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ)។ រីឯ តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានរបស់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវស្នើឡើងដោយសាមីមន្ទីរជំនាញរាជធានី ខេត្ត និងត្រូវពិនិត្យនិងចុះហត្ថលេខាដោយប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រធានរតនាគាររាជធានី ខេត្ត (ដូចមានកំណត់ជាឧបសម្ព័ន្ធទី១.១ នៃប្រកាសនេះ)។ ចំពោះគំរូលិខិតស្នើសុំបង្កើតរដ្ឋទេយ្យបុរេប្រទានរបស់មន្ទីរជំនាញរាជធានី ខេត្ត មានកំណត់ជាឧបសម្ព័ន្ធទី១.២ នៃប្រកាសនេះ។

២). ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ពិនិត្យ និងចុះហត្ថលេខា លើសេចក្តីសម្រេចស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន (ដូចមានកំណត់ជាឧបសម្ព័ន្ធទី២នៃប្រកាសនេះ)។ រីឯ ប្រធានរតនាគាររាជធានី ខេត្ត ត្រូវពិនិត្យនិងផ្តល់យោបល់លើសំណើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទានរបស់មន្ទីរជំនាញរាជធានី ខេត្ត (ដូចមានកំណត់ជាឧបសម្ព័ន្ធទី២.១នៃប្រកាសនេះ)។

៣). ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ពិនិត្យ និងចុះហត្ថលេខា លើសេចក្តីសម្រេចស្តីពីការតែងតាំងភ្នាក់ងារបើកផ្តល់ (ដូចមានកំណត់ជាឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ)។ រីឯ ប្រធានរតនាគាររាជធានី ខេត្ត ត្រូវពិនិត្យនិងផ្តល់យោបល់លើសំណើសុំតែងតាំងភ្នាក់ងារបើកផ្តល់របស់មន្ទីរជំនាញរាជធានី ខេត្ត (ដូចមានកំណត់ជាឧបសម្ព័ន្ធទី៣.១ នៃប្រកាសនេះ)។

**ប្រការ២.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសាផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. គាត ឈន់ (signature)

<u>**កន្លែងទទួល÷**</u>

- ក្រុមថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

គំរូសេចក្តីសម្រេចស្តីពីការបង្កើតរង្វាន់ទេយ្យបុរេប្រទាននៅមន្ទីរជំនាញរាជធានី ខេត្ត ដែលអនុវត្តថវិកាកម្មវិធី

### សេចក្តីសម្រេច
### ស្តីពី
### ការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ឆ្នាំ.....
### នៅមន្ទីរ.....រាជធានី/ខេត្ត............................

ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.... ប្រធានមន្ទីរ....រាជធានី/ខេត្ត...........

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ .............ចុះថ្ងៃទី....... ខែ........ ឆ្នាំ....... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.......
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ........ អនក្រ.បក ចុះថ្ងៃទី..... ខែ...... ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ......... (ក្រសួង/ស្ថាប័ន/អង្គភាព)
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ប.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក៦២ "អត្ថប្រយោជន៍សង្គម", ជំពូក៦៤ "បន្ទុកបុគ្គលិក", ជំពូក៦៥ "ឧបត្ថម្ភធន" នៅមន្ទីរ...រាជធានី/ខេត្ត....... សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃសេចក្តីសម្រេចនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

ប្រធានរតនាគាររាជធានី/ខេត្ត.. ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.. មន្ទីរ......រាជធានី/ខេត្ត.... ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានី/ខេត្ត.... ថ្ងៃទី ខែ ឆ្នាំ

**ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត....** **ប្រធានមន្ទីរ...រាជធានី/ខេត្ត....**

**កន្លែងទទួល៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង......(ជូនជ្រាប)
- ដូចប្រការ៤ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១.១

*(ឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីណែនាំស្តីពីការបង្កើតថវិកាបុរេប្រទាន សម្រាប់មន្ទីរជំនាញរាជធានី ខេត្ត- ថវិកាកម្មវិធី)*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង............

មន្ទីរ....

តារាងឧបសម្ព័ន្ធថវិកាបុរេប្រទានចំពោះការអនុវត្តឆ្នាំ....

របស់មន្ទីរ..................

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានថវិកាបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិលថវិកាបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/៤ជុំ | ៦= ៣/២ |
| | | | សរុបរួម (I+II) | | | | | | |
| I. ឥណទានតាមជំពូក ដោយមិនគិតបញ្ចូលចំណាយប្រាក់បេសកកម្មក្នុងប្រទេស | | | | | | | | | (ជំពូកនីមួយៗ មិនលើស៣០%) |
| 60 | | | ការទិញ | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | |
| | | 60011 | | | | | | | |
| | ... | .... | | | | | | | |
| 61 | | | សេវាកម្ម | | | | | | |
| | ..... | .... | | | | | | | |
| 64 | | | បន្ទុកបុគ្គលិក (ក្រៅពីប្រាក់បៀវត្ស) | | | | | | |
| | ..... | .... | | | | | | | |
| 62 | | | អត្ថប្រយោជន៍សង្គម | | | | | | |
| | ..... | .... | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | |
| | ..... | .... | | | | | | | |
| II. ឥណទានប្រាក់បេសកកម្មក្នុងប្រទេស | | | | | | | | | (១០០%) |
| 61 | | | សេវាកម្ម | | | | | | |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | | | | | | |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | | | | | | |
| | | 61122 | សោហ៊ុយបេសកកម្ម | | | | | | |
| | | 61123 | សោហ៊ុយស្នាក់នៅ | | | | | | |
| | | 61128 | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | | | |

| | | | |
|---|---|---|---|
| ថ្ងៃទី.....ខែ.......ឆ្នាំ.... | ថ្ងៃទី.....ខែ.......ឆ្នាំ.... | ថ្ងៃទី.....ខែ.......ឆ្នាំ.... | ថ្ងៃទី.....ខែ.......ឆ្នាំ.... |
| ប្រធានរតនាគាររាជធានី/ខេត្ត... | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត..... | ប្រធានមន្ទីរ.....រាជធានី/ខេត្ត..... | ថវិកាបុរេប្រទាន |



ឧបសម្ព័ន្ធទី១.២

គំរូលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទានរបស់មន្ទីរជំនាញរាជធានី ខេត្ត

ដែលអនុវត្តថវិកាកម្មវិធី

ព្រះរាជាណាចក្រកម្ពុជា

ក្រសួង....

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរ........

ប្រធានមន្ទី....រាជធានី/ខេត្ត......

សូមគោរពជូនលោក/លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...

តាមរយៈ÷ លោក/លោកស្រីប្រធានរតនាគាររាជធានី/ខេត្ត...

កម្មវត្ថុ÷ សំណើបង្កើតរជ្ជទេយ្យបុរេប្រទាននៅមន្ទីរ....រាជធានី/ខេត្ត....

យោង÷ - សៀវភៅថវិកានៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.....

- អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូនលោក/លោកស្រីប្រធាន មេត្តាជ្រាបថា÷ ដោយថវិកាឆ្នាំ....នៅមន្ទីរ...រាជធានី/ខេត្ត មានការប្រែប្រួល និងដោយមានការចាំបាច់សម្រាប់ចំណាយលើដំណើរការរដ្ឋបាលមន្ទីរ....រាជធានី/ខេត្ត...ស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ.... ដោយកំណត់ទឹកប្រាក់ក្នុង០១ជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ស្មើនឹង......(តួលេខទឹកប្រាក់ជាអក្សរ)។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រីប្រធាន មេត្តាពិនិត្យនិងសម្រេច ឱ្យមន្ទីរ.......... រាជធានី/ខេត្ត....បានបង្កើតរជ្ជទេយ្យបុរេប្រទាន តាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅរាជធានី/ខេត្ត.... ថ្ងៃទី...ខែ.....ឆ្នាំ......

ប្រធានមន្ទីរ.....រាជធានី/ខេត្ត.....

លេខ......

បានឃើញ និង.............

ថ្ងៃទី......ខែ.........ឆ្នាំ........

ប្រធានរតនាគាររាជធានី/ខេត្ត......

ឧបសម្ព័ន្ធទី២

គំរូសេចក្តីសម្រេចស្តីពីការតែងតាំងរដ្ឋលេខាធិការប្រចាំមន្ទីរជំនាញរាជធានី ខេត្ត

ដែលអនុវត្តថវិកាកម្មវិធី

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងរដ្ឋលេខាធិការប្រចាំ

## នៅមន្ទីរ.....រាជធានី/ខេត្ត...........................

—~—

## ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.....

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ............ចុះថ្ងៃទី.....ខែ.......ឆ្នាំ.........ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.......
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ........ អនក្រ.បក ចុះថ្ងៃទី..... ខែ...... ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ.........(ក្រសួង/ស្ថាប័ន/អង្គភាព)

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

**សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការ នៃមន្ទីរ....រាជធានី/ខេត្ត......... ដូចខាងក្រោម÷

១- លោក/លោកស្រី .............(ឈ្មោះ) ................. (មុខងារ) ជារជ្ជទេយ្យករបុរេប្រទាននៅមន្ទីរ.........

២- លោក/លោកស្រី .............(ឈ្មោះ) ......................(មុខងារ) ជារជ្ជទេយ្យករបុរេប្រទានរងនៅមន្ទីរ.........។

(តែងតាំងតាមការចាំបាច់)

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

ប្រធានរតនាគាររាជធានី/ខេត្ត.. ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.. មន្ទីរ......រាជធានី/ខេត្ត....ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានី/ខេត្ត....ថ្ងៃទី......ខែ........ឆ្នាំ..........

**ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.....**

**កន្លែងទទួល÷**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង......(ជូនជ្រាប)
- ដូចប្រការ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី២.១.

គំរូលិខិតស្នើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទាននៅមន្ទីរជំនាញរាជធានី ខេត្ត
ដែលអនុវត្តថវិកាកម្មវិធី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង....

មន្ទីរ........

ប្រធានមន្ទីរ....រាជធានី/ខេត្ត......

សូមគោរពជូនលោក/លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...

តាមរយៈ÷ លោក/លោកស្រីប្រធានរតនាគាររាជធានី/ខេត្ត...

កម្មវត្ថុ÷ សំណើតែងតាំងរដ្ឋទេយ្យករបុរេប្រទាននៅមន្ទីរ....រាជធានី/ខេត្ត....

យោង÷ - អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាតិទូទៅនៃគណនេយ្យសាធារណៈ
- ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- តម្រូវការចាំបាច់របស់មន្ទីរ...រាជធានី/ខេត្ត....

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូនលោក/លោកស្រីប្រធាន មេត្តាជ្រាបថា÷ ដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុរបស់មន្ទីរ...រាជធានី/ខេត្ត... បានល្អប្រសើរ ស្របតាមបទបញ្ញាតិទូទៅនៃគណនេយ្យសាធារណៈ មន្ទីរ...រាជធានី/ខេត្ត... ស្នើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទាន ដែលមានរាយនាមដូចខាងក្រោម÷

១. លោក/លោកស្រី ..........(ឈ្មោះ) ............ (មុខងារ) ជារដ្ឋទេយ្យករបុរេប្រទាននៅមន្ទីរ...រាជធានី/ខេត្ត......
២. លោក/លោកស្រី .........(ឈ្មោះ) ............(មុខងារ) ជារដ្ឋទេយ្យករបុរេប្រទានរងនៅមន្ទីរ...រាជធានី/ខេត្ត.....។
(តែងតាំងតាមការចាំបាច់)

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រីប្រធាន មេត្តាពិនិត្យនិងសម្រេចតែងតាំងមន្ត្រី ដូចបានស្នើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានី/ខេត្ត.... ថ្ងៃទី.....ខែ......ឆ្នាំ.......
ប្រធានមន្ទីរ.....រាជធានី/ខេត្ត.....

លេខ......
បានឃើញ និង.............
ថ្ងៃទី......ខែ.........ឆ្នាំ.........
ប្រធានរតនាគាររាជធានី/ខេត្ត......

**ឧបសម្ព័ន្ធទី៣.១**

គំរូលិខិតស្នើសុំតែងតាំងភ្នាក់ងារបើកផ្តល់នៅមន្ទីរជំនាញរាជធានី ខេត្ត

ដែលអនុវត្តថវិកាកម្មវិធី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង....**

**មន្ទីរ........**

**ប្រធានមន្ទី....រាជធានី/ខេត្ត......**

**សូមគោរពជូនលោក/លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...**

**តាមរយៈ÷** លោក/លោកស្រីប្រធានរតនាគាររាជធានី/ខេត្ត...

**កម្មវត្ថុ÷** សំណើតែងតាំងភ្នាក់ងារបើកផ្តល់នៅមន្ទីរ....រាជធានី/ខេត្ត....

**យោង÷** - អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

- តម្រូវការចាំបាច់របស់មន្ទីរ...រាជធានី/ខេត្ត....

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូនលោក/លោកស្រីប្រធាន មេត្តាជ្រាបថា÷ ដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុរបស់មន្ទីរ...រាជធានី/ខេត្ត... បានល្អប្រសើរ ស្របតាមបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ មន្ទីរ...រាជធានី/ខេត្ត...ស្នើសុំតែងតាំងវជ្ជទេយ្យករបុរេប្រទាន ដែលមានរាយនាមដូចខាងក្រោម÷

១. លោក/លោកស្រី ..........(ឈ្មោះ) ............ (មុខងារ) ជាភ្នាក់ងារបើកផ្តល់នៅមន្ទីរ...រាជធានី/ខេត្ត.....

២. លោក/លោកស្រី .........(ឈ្មោះ) ...........(មុខងារ) ជាភ្នាក់ងារបើកផ្តល់ជំនួសនៅមន្ទីរ...រាជធានី/ខេត្ត.....។

(តែងតាំងតាមការចាំបាច់)

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រីប្រធាន មេត្តាពិនិត្យនិងសម្រេចតែងតាំងមន្ត្រី ដូចបានស្នើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅរាជធានី/ខេត្ត....ថ្ងៃទី.......ខែ.....ឆ្នាំ......

**ប្រធានមន្ទីរ.....រាជធានី/ខេត្ត.....**

លេខ......

បានឃើញ និង.............

ថ្ងៃទី......ខែ.........ឆ្នាំ.........

**ប្រធានរតនាគាររាជធានី/ខេត្ត......**

ឧបសម្ព័ន្ធទី៣

គំរូសេចក្តីសម្រេចស្តីពីការតែងតាំងភ្នាក់ងារបើកផ្តល់នៅមន្ទីររដ្ឋធានី ខេត្ត

ដែលអនុវត្តថវិកាកម្មវិធី

## សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងភ្នាក់ងារបើកផ្តល់

## នៅមន្ទីរ.....រាជធានី/ខេត្ត...........................

---

### ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត........

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ............ ចុះថ្ងៃទី.....ខែ.......ឆ្នាំ......... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ.......
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ........ អនក្រ.បក ចុះថ្ងៃទី..... ខែ...... ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ.........(ក្រសួង/ស្ថាប័ន/អង្គភាព)

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

**សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការ នៃមន្ទីរ....រាជធានី/ខេត្ត......... ដូចខាងក្រោម÷

៣- លោក/លោកស្រី .............(ឈ្មោះ) .................. (មុខងារ) ជាភ្នាក់ងារបើកផ្តល់នៅមន្ទីរ.........

៤- លោក/លោកស្រី .............(ឈ្មោះ) ......................(មុខងារ) ជាភ្នាក់ងារបើកផ្តល់ជំនួសនៅមន្ទីរ.........។

(តែងតាំងតាមការចាំបាច់)

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

ប្រធានរតនាគាររាជធានី/ខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានមន្ទីរ......រាជធានី/ខេត្ត....ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានី/ខេត្ត.... ថ្ងៃទី.......ខែ.........ឆ្នាំ.......

**ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី/ខេត្ត.....**

**កន្លែងទទួល÷**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង......(ជូនជ្រាប)
- ដូចប្រការ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ